ក

# មាតិកា

## I.-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៦០ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈចំពោះ សពលោកជំទាវ **តូ ឆៀន ឆេព ១៩** នូវគ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ ១៨១៨

១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៦១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និង អស់លោក ចំនួន ០៩ រូប ១៨១៩

១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៦២ ស្តីពី ការបង្កើតគណៈឱសថការីកម្ពុជា ១៨២០

១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៦៣ ស្តីពី ប្រព័ន្ធមតិកមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា ១៨៣២

១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៦៤ ស្តីពី ការប្រគល់ភារកិច្ចជូន ឯកឧត្តម **ហាប់ ទូច** ឱ្យបំពេញមុខងារជា អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជំនួសឯកឧត្តម **មាស សារូន** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ១៨៣៩

១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៦៥ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ លោកឧកញ៉ា **ឌឹម សុនផល** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ១៨៤០

១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៦៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ ឯកឧត្តម និង លោកជំទាវ ចំនួន ០៤ រូប ១៨៤១

១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៦៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ លោកជំទាវ,លោកឧកញ៉ា និង អស់លោក ចំនួន ២០ រូប ១៨៤២

១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៦៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម,លោកជំទាវ, អស់លោក និង លោកស្រី ចំនួន ១៣ រូប ១៨៤៣

១៧-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៧១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ អស់លោក ជាកងកម្លាំងប្រដាប់អាវុធ ចំនួន ១៣ រូប ១៨៤៤

១៧-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៧២ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ លោកជំទាវ Zhang Jinfeng នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ១៨៤៥

## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ

២៤-០២-២០១០ -អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ទ្រព្យសម្បត្តិសាធារណៈ របស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ១៨៤៦

២៤-០២-២០១០ -អនុក្រឹត្យលេខ ២៨ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារ ធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ១៨៤៩

១៦-០២-២០១០ -អនុក្រឹត្យលេខ ១៥៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៨៥១

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៥៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨៥២

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៥៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៨៥៤

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៥៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨៥៦

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៦០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨៥៨

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៦១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៨៦០

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៦២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨៦២

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៦៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨៦៤

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៦៤ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៨៦៦

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៦៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨៦៧

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៦៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៨៧២

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៦៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨៧៣

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៦៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៨៧៤

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៦៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨៧៥

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៧០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨៧៦

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៧១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨៧៧

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៧២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨៧៩

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៧៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ត្រីវឌ្ឍនា ១៨៨០

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៧៤ អនក្រ.តត ស្តីពី ការបញ្ចូលក្របខ័ណ្ឌ និង ប្រគល់ ឋានន្តរស័ក្តិ នាយទាហាន ១៨៩១

១៧-០២-២០១០ -អនុក្រឹត្យលេខ ១៧៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨៩២
១៧-០២-២០១០ -អនុក្រឹត្យលេខ ១៧៦ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៨៩៣
១៧-០២-២០១០ -អនុក្រឹត្យលេខ ១៧៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨៩៤
១៧-០២-២០១០ -អនុក្រឹត្យលេខ ១៧៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៨៩៧
១៧-០២-២០១០ -អនុក្រឹត្យលេខ ១៧៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨៩៨
១៧-០២-២០១០ -អនុក្រឹត្យលេខ ១៨០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៨៩៩
១៧-០២-២០១០ -អនុក្រឹត្យលេខ ១៨១ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៩០១
១៧-០២-២០១០ -អនុក្រឹត្យលេខ ១៨២ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ១៩០៣

## ២-សេចក្តីសម្រេច

២៥-០២-២០១០ -សេចក្តីសម្រេចលេខ ១០ សសរ ស្តីពី ការចងសម្ព័ន្ធមេត្រីភាព រវាងអង្គភាព កងទ័ព អង្គភាពស៊ីវិល ១៩០៤

## ៣-សារាចរណែនាំ

២៤-០២-២០១០ -សារាចរណែនាំលេខ ០១ សរណន ស្តីពី ការរៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ២ ឆ្នាំ ២០១០ ១៩០៦

## III-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៣០-៤-២០០៩ -លិខិតបញ្ជាក់លេខ ១៨៦៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពន្លឺ ស័ក្តិសិទ្ធិ** ១៩០៩
៣០-៤-២០០៩ -លិខិតបញ្ជាក់លេខ ១៨៦៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ី.អឹម.អូ រីសៃសស៍ គ្រុប** ១៩១១
៣០-៤-២០០៩ -លិខិតបញ្ជាក់លេខ ១៨៧០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុផន លីគុន គ្រុប** ១៩១៣
០៤-៥-២០០៩ -លិខិតបញ្ជាក់លេខ ១៨៧១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មីរ៉ាខល អេច ខេ អេស អាយ & ស៊ី** ១៩១៥
០៤-៥-២០០៩ -លិខិតបញ្ជាក់លេខ ១៨៧៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុខ សេន ហៃ (ខេមបូឌា)** ១៩១៧
០៤-៥-២០០៩ -លិខិតបញ្ជាក់លេខ ១៨៧៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស.ខូខា** ១៩១៩

| | | |
|---|---|---|
| ០៤-៥-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៧៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេន ចាយា** | ១៩២១ |
| ០៤-៥-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៧៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រីហ្វិតខូដ អ៊ិនធើណេសិនណល (ខេមបូឌា) លីមីធីត** | ១៩២៣ |
| ០៤-៥-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៨០ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជី នូវការបង្កើត ការិយាល័យតំណាងពាណិជ្ជកម្ម នៃក្រុមហ៊ុន **អូលត្រ៉ា ឌីវេឡុបមេន តិចអ៊ិ អេស៊ា អិលធីឌី** (ចុះបញ្ជីនៅប្រទេសសិង្ហបូរី) ប្រចាំព្រះរាជាណាចក្រកម្ពុជា | ១៩២៥ |
| ០៤-៥-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆាន ឆាន ត្រេនស្ព័ត & អ៊ីមផត អិចផត** | ១៩២៦ |
| ០៤-៥-២០០៩ | -លិខិតបញ្ជាក់លេខ ១៨៩៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច.ប្រាឌើរ** | ១៩២៨ |
| ០៥-៥-២០០៩ | -លិខិតបញ្ជាក់លេខ ១៩០៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខែលតូ ខូ អិលធីឌី** | ១៩៣០ |
| ០៥-៥-២០០៩ | -លិខិតបញ្ជាក់លេខ ១៩០៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដេនេរ៉ល អេនើជី គ្រុប** | ១៩៣២ |

# ព្រះរាជក្រឹត្យ

**យើង**

នស/រកត/០២១០/១៦០

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ជាតិក្ខបណ្ឌាមរណៈ**

ចំពោះ

សពលោកជំទាវ **ភួ ភៀន ធេព ខន**

នូវ គ្រឿងឥស្សរិយយស

**សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍**

៣៖៧.១០០៧.១៦៧

**បានប្រថាប់ព្រះរាជលញ្ឆករហើយ** **នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

លេខ ០០៤៦/១០ .. រ.ចច

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ... ខែ កុម្ភៈ.... ឆ្នាំ ២០១០

សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ព្រះបរម...

គង់ សំអុល

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ៖
១-ឯកឧត្តម ខឹម សោភ័ណ ៣-ឯកឧត្តម ហេង រតនា
២-ឯកឧត្តម ជុំ ប៊ុនរ៉ុង
ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ៖
ឯកឧត្តម អ៊ុំ ភូមីរ៉ា
គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ៖
១-លោក ឯក បូលីន ៤-លោក អ៊ុំ សង់អ៊ុន
២-លោក ឡេង ប្រាង ៥-លោក យុន រតនា
៣-លោក រាត់ ភានិត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/៧. ១០០៤. ១៦៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០

លេខៈ ១៥០ ច.ល
សម្រាប់ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦២

**ស្តីពី**

**ការបង្កើតគណៈឱសថការីកម្ពុជា**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខជស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/១២០៧/០៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រ

ROYAUME DU CAMBODGE * LE MINISTÈRE ... ROYAL * ព្រះរាជវាំង

- បានទ្រង់យល់ព្រះរាជក្រមលេខជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០១០

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

បង្កើត**គណៈឱសថការីកម្ពុជា**មួយ ដើម្បីប្រមូលផ្តុំឱសថការីទាំងអស់ដែលមាននីតិសម្បទាគ្រប់គ្រាន់ អាចប្រកបវិជ្ជាជីវៈឱសថសាស្ត្រ និងអមវេជ្ជសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា។

ពាក្យថា ឱសថការី ក្នុងព្រះរាជក្រឹត្យនេះ គឺនីតិជនដែលមានសញ្ញាបត្រឱសថសាស្ត្រ ចេញដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា ឬសញ្ញាបត្រឱសថសាស្ត្រ ចេញដោយគ្រឹះស្ថានឧត្តមសិក្សាដែលបានទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

ឱសថការីទាំងអស់ដែលប្រកបវិជ្ជាជីវៈឱសថសាស្ត្រ និងអមវេជ្ជសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែសុំចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា។

## ជំពូកទី២

## បេសកកម្មនិងតួនាទីរបស់គណៈឱសថការីកម្ពុជា

### ផ្នែកទី១

### បេសកកម្ម

**មាត្រា២.-**

គណៈឱសថការីកម្ពុជា តាមរយៈការចូលរួមការបំពេញសេវាសាធារណៈផ្នែកសុខភាពសាធារណៈ ទទួលបាននូវបុព្វសិទ្ធិដែលរដ្ឋប្រគល់ជូន។

គណៈឱសថការីកម្ពុជា ធានាមើលការប្រព្រឹត្តទៅនៃបណ្តាគោលការណ៍ សីលធម៌ ភាពសុចរិត យុត្តិធម៌ និងភក្តីភាពចាំបាច់ ក្នុងការប្រកបវិជ្ជាជីវៈឱសថសាស្ត្រ អមវេជ្ជសាស្ត្រឱ្យបានគង់វង្ស និងមានប្រសិទ្ធភាព។

គណៈឱសថការីកម្ពុជា ធានាមើលការប្រតិបត្តិរបស់សមាជិកខ្លួនទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងក្រមសីលធម៌ឱសថការី។

គណៈឱសថការីកម្ពុជា ធានាការពារកិត្តិយស និងឥស្សរភាពរបស់វិជ្ជាជីវៈឱសថសាស្ត្រ និងអមវេជ្ជសាស្ត្រ។

គណៈឱសថការីកម្ពុជា បំពេញភារកិច្ចរបស់ខ្លួនតាមរយៈក្រុមប្រឹក្សាគណៈឱសថការីរាជធានី ខេត្តដែលសរសេរអក្សរកាត់ថាគ.ឱ.រ.ខ. ក្រុមប្រឹក្សាគណៈឱសថការីភូមិភាគដែលសរសេរអក្សរកាត់ថា **គ.ឱ.ភ.** និងក្រុមប្រឹក្សាគណៈឱសថការីជាតិដែលសរសេរអក្សរកាត់ថា**គ.ឱ.ជ.** ។

## ផ្នែកទី២
## តួនាទីសីលធម៌

**មាត្រា៣.-**

គណៈឱសថការីកម្ពុជា មានបន្ទុករៀបរៀងក្រមសីលធម៌ឱសថការី យកលំនាំតាមលក្ខណៈចាំបាច់នៃវិជ្ជាជីវៈក្នុងការវិវឌ្ឍ ខាងបច្ចេកទេស សេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ ។

គណៈឱសថការីកម្ពុជា ត្រូវឃ្លាំមើលរាល់ការប្រតិបត្តិកិច្ចការ និងសេចក្តីគោរពប្រណិប័តន៍របស់ឱសថការី ។

គណៈឱសថការីកម្ពុជា ជាអង្គការស្វយ័ត ។ ការចំណាយ ការផ្គត់ផ្គង់ប្រាក់កាស ម្ចាស់ការខ្លួនឯង ធានាឥស្សរភាព ការពារផលប្រយោជន៍សីលធម៌វិជ្ជាជីវៈ ។

## ផ្នែកទី៣
## តួនាទីគ្រប់គ្រងរដ្ឋបាល

**មាត្រា៤.-**

ការចាត់ចែងអំណាចត្រូវអនុលោមតាមបទបញ្ជាគណៈឱសថការីកម្ពុជា ។

គណៈឱសថការីកម្ពុជា ត្រូវរៀបចំធ្វើនិងថែរក្សាទុកជាប្រចាំនូវបញ្ជីរាយនាមឱសថការី ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា ដើម្បីបំពេញលក្ខខណ្ឌច្បាប់ និងសីលធម៌ចាំបាច់ ។

កាតព្វកិច្ចនៃការចុះឈ្មោះក្នុងបញ្ជីរាយនាមឱសថការី គឺដើម្បីបំពេញការងារឱសថសាស្ត្រ និងអមវេជ្ជសាស្ត្រ ។

គណៈឱសថការីកម្ពុជា ជាអង្គការវិជ្ជាជីវៈតែមួយគត់ ដែលមានមុខងារតាមឃ្លាំមើលលក្ខខណ្ឌនៃការប្រកបវិជ្ជាជីវៈឱសថសាស្ត្រ អមវេជ្ជសាស្ត្រនេះ ។

## ផ្នែកទី៤
## តួនាទីសម្រេចសេចក្តីតាមបែបតុលាការ

**មាត្រា៥.-**

ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងការងារវិន័យវិជ្ជាជីវៈ **គ.ឱ.ភ.** ត្រូវអនុវត្តការងារជាយន្តការយុត្តាធិការ ។

បណ្តឹងអំពីការប្រព្រឹត្តខុសឆ្គងនៃមុខវិជ្ជាជីវៈរបស់ឱសថការីណាម្នាក់ ទៅគណៈឱសថការីកម្ពុជា មិនមែនជាឧបសគ្គក្នុងការដាក់ពាក្យបណ្តឹងអំពីការប្រព្រឹត្តខុសឆ្គងនេះទៅតុលាការឡើយ ។

## ផ្នែកទី៥
## តួនាទីពិភាក្សាផ្ដល់យោបល់

**មាត្រា៦._**

គណៈឱសថការីកម្ពុជាអាចត្រូវបានអញ្ជើញឱ្យផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិជ្ជាជីវៈឱសថសាស្ត្រទាំងឡាយ ។

## ផ្នែកទី៦
## តួនាទីជួយសង្គ្រោះគ្នាទៅវិញទៅមក

**មាត្រា៧._**

ការជួយសង្គ្រោះគ្នាទៅវិញទៅមកនេះមានបច្ច័យល្អដល់ឱសថការី និងគ្រួសាររបស់គេ។ ការជួយសង្គ្រោះគ្នា ត្រូវរៀបចំតាមបែបបទដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុង អនុម័តដោយមហាសន្និបាតៈ

- គណៈឱសថការីកម្ពុជា ត្រូវមានក្នុងថវិការបស់ខ្លួននូវប្រាក់បម្រុងសម្រាប់សង្គ្រោះគ្នាទៅវិញទៅមក ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ប្រាក់បម្រុងជាជំនួយភ្លាមៗ ក្នុងករណីសមរម្យដល់គ្រួសារឱសថការី ដែលត្រូវវង្វេទុក្ខលំបាក
- គណៈឱសថការីកម្ពុជា ត្រូវមានគណៈកម្មការមួយជួយសង្គ្រោះគ្នាទៅវិញទៅមក ដែលមានតំណាងសមាគមឱសថការីកម្ពុជាម្នាក់ជាសមាជិក
- គណៈកម្មការនេះចាត់ចែងឱ្យមានធនធានប្រចាំឆ្នាំ ដែលកាត់យកខ្លះពីប្រាក់ភាគទានរបស់ឱសថការីម្នាក់ៗ ដែលចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា ។

## ជំពូកទី៣
## រចនាសម្ព័ន្ធ
## ផ្នែកទី១
## ក្រុមប្រឹក្សាគណៈឱសថការីរាជធានី ខេត្ត

**មាត្រា៨._**

**គ.ឱ.រ.ខ.** ត្រូវបានបង្កើតនៅតាមរាជធានី ខេត្តនីមួយៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

រាជធានី ខេត្ត ដែលមានចំនួនឱសថការីតិចជាង១០(ដប់)រូប ត្រូវបញ្ចូនទៅខេត្តដែលនៅជិតជាងគេ ដើម្បីបង្កើតក្រុមប្រឹក្សាគណៈឱសថការីរួមគ្នា ។

**មាត្រា៩._**

**គ.ឱ.រ.ខ.** ត្រូវមានសមាជិកពេញសិទ្ធិចំនួន៣(បី)រូប និងសមាជិកជំនួសចំនួន៣(បី)រូប ក្នុងករណីដែលឱសថការីចុះបញ្ជីមានចំនួនមិនលើសពី៣០(សាមសិប)រូប ។ ចំនួននេះនឹងឡើងទៅដល់៥(ប្រាំ) ៧(ប្រាំពីរ) ៩(ប្រាំបួន) ១១(ដប់មួយ)

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ឬ១៣(ដប់បី)រូប ប្រសិនបើឱសថការីចុះបញ្ជីមានចំនួនពី ៣០(សាមសិប)រូប ៥០(ហាសិប)រូប ១០០(មួយរយ)រូប ១ ០០០ (មួយពាន់)រូប ឬ២ ០០០ (ពីរពាន់)រូប ។

**មាត្រា១០.-**

**គ.ឱ.រ.ខ.**ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងអង្គមហាសន្និបាត ដោយឱសថការីទាំងឡាយ ដែលបានចុះឈ្មោះនៅក្នុងបញ្ជីរបស់**គ.ឱ.រ.ខ.**សម្រាប់រយៈពេល៦ (ប្រាំមួយ) ឆ្នាំ ។

សមាជិកចប់អាណត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងសមាសភាពនៃការិយាល័យរបស់ខ្លួននៅក្នុងរយៈពេល២(ពីរ) ឆ្នាំម្តង ក្រោយពេលធ្វើការផ្លាស់ប្តូរចំនួន១/៣(មួយភាគបី) នៃសមាជិកក្រុមប្រឹក្សា ហើយត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង អំពីករណីដែលសមាជិកផ្លាស់ប្តូរមានចំនួនចែកមិនដាច់ ។

សមាសភាពការិយាល័យរបស់**គ.ឱ.រ.ខ.** រួមមានប្រធានក្រុមប្រឹក្សា១(មួយ)រូប អនុប្រធាន១(មួយ)រូប លេខាធិការ១ (មួយ)រូប ហេរញ្ញិក១ (មួយ)រូប និងសមាជិក១ (មួយ)រូប ។

**មាត្រា១១.-**

**គ.ឱ.រ.ខ.**បំពេញការងារនៅក្នុងក្របខណ្ឌរាជធានីខេត្តរបស់ខ្លួន និងក្រោមការត្រួតពិនិត្យរបស់គណៈឱសថការីកម្ពុជា ចំពោះសមត្ថកិច្ចទូទៅទាំងឡាយដែលមានចែងក្នុងមាត្រា២នៃព្រះរាជក្រឹត្យនេះ ។

**គ.ឱ.រ.ខ.**សម្រេចអារកាត់ក្នុងការចុះឈ្មោះឱសថការី ដែលបានបំពេញលក្ខខណ្ឌតាមមាត្រា៤ថ្មី នៃជំពូកទី១ មាត្រា៧ និង មាត្រា៨ថ្មីនៃជំពូកទី៣ នៃច្បាប់ស្តីពីការគ្រប់គ្រងឱសថ មាត្រា៦នៃជំពូកទី២ និងមាត្រា១០នៃជំពូកទី៣នៃច្បាប់ស្តីពីការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ក្នុងបញ្ជីរបស់**គ.ឱ.រ.ខ.** ។

**គ.ឱ.រ.ខ.**មិនប្រកាន់ភេទ ជំនឿ សាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតរបស់សមាជិកខ្លួនឡើយ ។

**មាត្រា១២.-**

**គ.ឱ.រ.ខ.**ពុំមានអំណាចជាគិរិន័យទេ ។ បើមានពាក្យប្តឹងចំពោះឱសថការីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន **គ.ឱ.រ.ខ.** ត្រូវបញ្ជូនបណ្តឹងនេះទៅ**គ.ឱ.ក.**ដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។

**មាត្រា១៣.-**

ប្រធានជាតំណាងរបស់**គ.ឱ.រ.ខ.**នៅក្នុងគ្រប់សកម្មភាពស៊ីវិល ។



**មាត្រា១៤.-**

ការប្រជុំនៃគ.ឱ.រ.ខ.មិនធ្វើជាសាធារណៈឡើយ។ រាល់ការប្រជុំបើមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាពសម្រេច។ ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាគ្រាន់តែមានសំឡេងពិគ្រោះយោបល់។ **គ.ឱ.រ.ខ.**អាចអញ្ជើញទីប្រឹក្សាច្បាប់១(មួយ)រូប មកចូលរួមក្នុងអង្គប្រជុំ។

**មាត្រា១៥.-**

ឱសថការីនៅតាមបណ្ដារាជធានី ខេត្ត ត្រូវដាក់ពាក្យសុំចុះឈ្មោះនៅក្នុងបញ្ជីដែលកាន់កាប់ជាប្រចាំដោយ**គ.ឱ.រ.ខ.**ពាក់ព័ន្ធ។ ឱសថការីដែលសុំចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា ត្រូវតែមានសញ្ញាបត្រឱសថការីចេញដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា ឬសញ្ញាបត្រចេញដោយគ្រឹះស្ថានឧត្ដមសិក្សា ដែលទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងការប្រកបវិជ្ជាជីវៈឱសថសាស្ត្រ អមវេជ្ជសាស្ត្រ និងបានបំពេញលក្ខខណ្ឌច្បាប់ និងក្រមសីលធម៌ ដែលបានកំណត់។

ឱសថការីអាចចុះឈ្មោះបានតែនៅក្នុងបញ្ជីគណៈឱសថការីនៃរាជធានី ខេត្ត ដែលជាកន្លែងប្រកបវិជ្ជាជីវៈរបស់ខ្លួនតែប៉ុណ្ណោះ។

**មាត្រា១៦.-**

**គ.ឱ.រ.ខ.**ត្រូវសម្រេចលើសំណើសុំចុះឈ្មោះក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលពាក្យសុំដែលមានឯកសារគ្រប់គ្រាន់។

ក្នុងរយៈពេល១(មួយ)សប្ដាហ៍យ៉ាងយូរក្រោយការសម្រេច ក្រុមប្រឹក្សាត្រូវជូនដំណឹងតាមលិខិតអនុសាសន៍ទៅឱសថការីសាមី។ បើមានការបដិសេធលើសំណើសុំចុះឈ្មោះ **គ.ឱ.រ.ខ.**ត្រូវបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ។

បន្ទាប់ពីការអនុញ្ញាតឱ្យចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីរាជធានីខេត្តនីមួយៗរួចហើយ **គ.ឱ.រ.ខ.**ត្រូវជូនដំណឹងយ៉ាងយូរ២(ពីរ)សប្ដាហ៍ ទៅអាជ្ញាធររាជធានីខេត្ត ទៅព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីខេត្តពាក់ព័ន្ធ និងទៅ**គ.ឱ.ជ.**។

**មាត្រា១៧.-**

ក្រោយពេលអនុញ្ញាតឱ្យចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីរាជធានី ខេត្ត ដែលខ្លួនកំពុងប្រកបវិជ្ជាជីវៈ ឱសថការីអាចប្រកបវិជ្ជាជីវៈឱសថសាស្ត្រ អមវេជ្ជសាស្ត្រ នៅរាជធានី ខេត្ត ដែលខ្លួនចុះឈ្មោះប៉ុណ្ណោះ។ ក្នុងករណីមានការផ្លាស់ប្ដូរលំនៅឋានទៅប្រកបវិជ្ជាជីវៈនៅក្រៅរាជធានី ខេត្ត ដែលខ្លួនចុះឈ្មោះ ឱសថការីត្រូវជូនដំណឹងទៅក្រុមប្រឹក្សាចាស់ និងត្រូវធ្វើពាក្យសុំចុះឈ្មោះសាជាថ្មីទៅ**គ.ឱ.រ.ខ.** ដែលខ្លួនទៅរស់នៅប្រកបវិជ្ជាជីវៈ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា១៨.-

គ.ឱ.រ.ខ.ត្រូវទទួលបណ្តឹងជំទាស់ពីគ.ឱ.៩. សមាគមឱសថការី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូង ឬឱសថការីណាម្នាក់ដែលចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីរាជធានី ខេត្តរបស់ខ្លួន រួចហើយធ្វើរបាយការណ៍ផ្ញើជូនគ.ឱ.៩.។

## ផ្នែកទី២
## ក្រុមប្រឹក្សាគណៈឱសថការីភូមិភាគ

មាត្រា១៩.-

ការបែងចែកភូមិភាគសម្រាប់គណៈឱសថការីកម្ពុជានេះ ត្រូវបានរៀបចំដូចខាងក្រោម ៖

-ភូមិភាគ១ មានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង មានទីតាំងនៅរាជធានីភ្នំពេញ

-ភូមិភាគ២ មានខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងប៉ៃលិន មានទីតាំងនៅខេត្តបាត់ដំបង

-ភូមិភាគ៣ មានខេត្តតាកែវ កំពត កោះកុង ព្រះសីហនុ និងកែប មានទីតាំងនៅខេត្តកំពត

-ភូមិភាគ៤ មានខេត្តស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ និងព្រះវិហារ មានទីតាំងនៅខេត្តស្ទឹងត្រែង

-ភូមិភាគ៥ មានខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង ស្វាយរៀង មានទីតាំងនៅខេត្តកំពង់ចាម ។

មាត្រា២០.-

គ.ឱ.ភ.មានតួនាទីជាក្រុមប្រឹក្សាវិន័យវិជ្ជាជីវៈថ្នាក់បឋម មានសមាជិកពេញសិទ្ធិចំនួន៥(ប្រាំ)រូប និងសមាជិកជំនួសចំនួន៥(ប្រាំ)រូប បោះឆ្នោតជ្រើសរើសក្នុងចំណោមគ.ឱ.រ.ខ.ក្នុងភូមិភាគ។ គ.ឱ.រ.ខ.នីមួយៗត្រូវជ្រើសរើសតំណាងរបស់ខ្លួនឱ្យបានយ៉ាងតិច១(មួយ)រូបជាសមាជិកពេញសិទ្ធិ និង១(មួយ)រូបជាសមាជិកជំនួស។ ចំនួនអាសនៈដែលនៅសល់ត្រូវបែងចែកទៅរាជធានី ខេត្ត ដោយផ្អែកលើចំនួនឱសថការីដែលចុះឈ្មោះជាសមាជិកក្រុមប្រឹក្សាភូមិភាគ។ សមាជិកក្រុមប្រឹក្សាភូមិភាគ ត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់រយៈពេល៦(ប្រាំមួយ)ឆ្នាំ។ សមាជិកចប់អាណត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាននិងសមាសភាពនៃការិយាល័យក្នុងរយៈពេល២(ពីរ)ឆ្នាំម្តង ក្រោយពេលធ្វើការផ្លាស់ប្តូរចំនួន១/៣(មួយភាគបី)នៃសមាជិកក្រុមប្រឹក្សា។ សមាជិកជំនួសត្រូវចូលជំនួសសមាជិកពេញសិទ្ធិ នៅពេលដែលសមាជិកនេះអវត្តមានដោយមូលហេតុអ្វីក៏ដោយ ។

សមាសភាពការិយាល័យគ.ឱ.ភ. រួមមានប្រធាន១ (មួយ)រូប អនុប្រធាន១ (មួយ)រូប លេខាធិការ១(មួយ)រូប ហេរញ្ញិក១ (មួយ)រូប និងសមាជិក១ (មួយ)រូប។

មាត្រា២១.-

ប្រធានគ.ឱ.រ.ខ. ប្រធានគ.ឱ.ភ. និងលេខាធិការនៃក្រុមប្រឹក្សាទាំងនេះ មិនអាចកាន់មុខងារត្រួតគ្នាបានឡើយ ។

**មាត្រា២២.-**

អង្គប្រជុំក.វិ.គ.ត្រូវមានការចូលរួមក្នុងឋានៈជាអនុប្រធាន និងជាអ្នកពិគ្រោះយោបល់របស់៖

- តំណាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្តដែលជាទីតាំងនៃក្រុមប្រឹក្សាភូមិភាគ
- ទីប្រឹក្សាច្បាប់មួយរូប ចាត់តាំងដោយក្រុមប្រឹក្សាអ្នកច្បាប់
- ឱសថការីការងារមួយរូប (បើមាន) ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ។

**មាត្រា២៣.-**

នៅក្នុងក្របខណ្ឌគណៈឱសថការី**ក.វិ.គ.**អនុវត្តការងាររបស់ខ្លួនតែលើសមត្ថកិច្ចខាងវិន័យតែប៉ុណ្ណោះ។

**ក.វិ.គ.**អាចទទួលបណ្តឹងជំទាស់ពី **ក.វិ.ជ.** **ក.វិ.រ.ខ.** សមាគមឱសថការី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាល អាជ្ញាធររាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ឬពីឱសថការីណាម្នាក់ ដែលចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា។

**ក.វិ.គ.**ត្រូវពិនិត្យសម្រេចក្នុងរយៈពេល៦(ប្រាំមួយ)ខែយ៉ាងយូរ ក្រោយពេលទទួលពាក្យប្តឹង។ បើមិនដូច្នោះទេ **ក.វិ.ជ.**អាចបញ្ជូនពាក្យប្តឹងនេះទៅ**ក.វិ.គ.**ណាមួយផ្សេងទៀតដែលបានជ្រើសរើស។

**មាត្រា២៤.-**

ឱសថការីដែលកំពុងបម្រើការនៅក្នុងសេវាសាធារណៈ ហើយសុំចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជាអាចបកស្រាយបានចំពោះមុខ**ក.វិ.គ.**អំពីសកម្មភាពក្នុងមុខងារសាធារណៈរបស់ខ្លួនតែតាមរយៈរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមរយៈប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬតាមរយៈព្រះរាជអាជ្ញាអមសាលាដំបូងតែប៉ុណ្ណោះ។

**មាត្រា២៥.-**

ការដាក់វិន័យត្រូវធ្វើឡើងនៅចំពោះមុខឱសថការីសាមី។ ឱសថការីសាមីអាចមានអ្នកការពារ ដែលជាឱសថការី ឬជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ប្រសិនបើឱសថការីសាមី មិនព្រមចូលខ្លួនមកបំភ្លឺ**ក.វិ.គ.**តាមការអញ្ជើញចំនួន ៣(បី)លើកដោយគ្មានមូលហេតុច្បាស់លាស់ **ក.វិ.គ.**ត្រូវអនុវត្តតាមចំណុចទី៤ក្នុងមាត្រា២៧នៃព្រះរាជក្រឹត្យនេះ។

**មាត្រា២៦.-**

**ក.វិ.គ.**ត្រូវមានបញ្ជីកត់ត្រានៅរាល់ពេលប្រជុំដាក់វិន័យ។ **ក.វិ.គ.**ត្រូវធ្វើកំណត់ហេតុត្រឹមត្រូវ ដោយមានការបញ្ជាក់និងមានការចុះហត្ថលេខាពីគ្រប់សមាជិកទាំងអស់នៃក្រុមប្រឹក្សា ព្រមទាំងហត្ថលេខារបស់សាមីជនដែលត្រូវចោទ

ROYAUME DU CAMBODGE ស្តីទីនេះដែល * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

**មាត្រា២៧.-**

ដោយមានការចូលរួមពីផ្នែកវិន័យនៃគ.ឱ.ខ. គ.ឱ.ភ.អាចដាក់វិន័យដល់សមាជិកដូចខាងក្រោម៖

- ការព្រមាន
- ការស្តីបន្ទោសដោយកត់ទុកនៅក្នុងឯកសារផ្ទាល់ខ្លួន
- ការហាមការប្រកបវិជ្ជាជីវៈមួយរយៈពេលមិនលើសពី៣(បី)ឆ្នាំ ឬជាអចិន្ត្រៃយ៍ ក្នុងផ្នែកណាមួយ ឬ ជាទូទៅនៃមុខងារឱសថសាស្ត្រ អមវេជ្ជសាស្ត្រ ដែលរដ្ឋទទួលស្គាល់
- ការលុបឈ្មោះចេញពីបញ្ជីគណៈឱសថការីកម្ពុជា ។

ឱសថការីដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណៈឱសថការីកម្ពុជា មិនអាចចុះឈ្មោះនៅកន្លែងណាផ្សេងទៀតបានឡើយ ។

សេចក្តីសម្រេចចុងក្រោយដែលបានលើកឡើង ត្រូវតែផ្សព្វផ្សាយទៅគ្រប់គ.ឱ.រ.ខ. ព្រមទាំងទៅគ.ឱ.ខ. ។ ការសម្រេចរបស់គ.ឱ.ភ.ត្រូវតែមានហេតុផលច្បាស់លាស់ ។

**មាត្រា២៨.-**

ក្រោយពេលទទួលវិន័យហាមការប្រកបវិជ្ជាជីវៈអស់រយៈពេល៣(បី)ឆ្នាំយ៉ាងតិចមក ឱសថការីដែលទទួលវិន័យអាចទទួលការលើកលែងវិន័យពីក្រុមប្រឹក្សាគណៈឱសថការីកម្ពុជា ដែលបានដាក់វិន័យដល់ខ្លួន។ ការសុំលើកលែងវិន័យនេះត្រូវធ្វើឡើងដោយឱសថការីសាមី។ កាលណាលិខិតស្នើសុំលើកលែងវិន័យនេះត្រូវបានបដិសេធ ក្រោយពេលធ្វើការពិនិត្យពិចារណាស៊ីជម្រៅមក ការស្នើសុំលើកលែងវិន័យសាជាថ្មីអាចធ្វើឡើងក្នុងរយៈពេល១(មួយ)ឆ្នាំទៅមុខទៀត។

ចំពោះវិន័យអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬជាទូទៅនៃមុខងារឱសថសាស្ត្រ អមវេជ្ជសាស្ត្រ ដែលរដ្ឋទទួលស្គាល់ មិនត្រូវអនុញ្ញាតឱ្យមានការស្នើសុំលើកលែងទេ។

**មាត្រា២៩.-**

ការអនុវត្តវិន័យចំពោះឱសថការី មិនមែនជាឧបសគ្គរាំងដល់ការអនុវត្តការដាក់វិន័យខាងរដ្ឋបាល ឬតុលាការឡើយ។

## ផ្នែកទី៣

## ក្រុមប្រឹក្សាគណៈឱសថការីជាតិ

**មាត្រា៣០.-**

គ.ឱ.ខ.ត្រូវបានជ្រើសរើសតាមការបោះឆ្នោតសម្រាប់រយៈពេល៦(ប្រាំមួយ)ឆ្នាំ បែងចែកដូចខាងក្រោម៖

- តំណាងខេត្តនីមួយៗចំនួន១(មួយ)រូប ជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាគណៈឱសថការីខេត្តនោះ។ អ្នកជាប់ឆ្នោតត្រូវបានតែងតាំងដោយប្រធានមន្ទីរសុខាភិបាលខេត្ត

- តំណាងរាជធានីចំនួន២ (ពីរ)រូប ជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាគណៈឱសថការីរាជធានី ។ អ្នកជាប់ឆ្នោតត្រូវបានតែងតាំងដោយប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ

- តំណាងអង្គភាពថ្នាក់កណ្តាលរបស់ក្រសួងសុខាភិបាលចំនួន៥(ប្រាំ)រូប ជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសហភាគរៈឱសថការី និងតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

- តំណាងមហាវិទ្យាល័យឱសថសាស្ត្រចំនួន១(មួយ)រូប ជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសហភាគរៈឱសថការី និងតែងតាំងដោយព្រឹទ្ធបុរសមហាវិទ្យាល័យ ។

**មាត្រា៣១.-**

**គ.ឱ.ជ.**ត្រូវធ្វើការជ្រើសរើសផ្លាស់ប្តូរសមាជិកចំនួន១/៣(មួយភាគបី)ក្នុងរយៈពេល២(ពីរ)ឆ្នាំម្តង ។ ក្រោយពីបានធ្វើការផ្លាស់ប្តូរសមាជិក១/៣(មួយភាគបី)ម្តងៗ **គ.ឱ.ជ.**ត្រូវធ្វើការជ្រើសរើសប្រធាន និងសមាសភាពការិយាល័យរបស់ខ្លួនសម្រាប់២ (ពីរ)ឆ្នាំម្តង ។

សមាសភាពការិយាល័យរបស់**គ.ឱ.ជ.**រួមមាន ៖

ប្រធានក្រុមប្រឹក្សា១(មួយ)រូប អនុប្រធានចំនួន២(ពីរ)រូប អគ្គលេខាធិការ១(មួយ)រូប អគ្គលេខាធិការរង១(មួយ)រូប ហេរញ្ញិក១(មួយ)រូប និងហេរញ្ញិករង១(មួយ)រូប ។ ប្រធាន និងសមាជិក**គ.ឱ.ជ.**ដែលចេញពីតំណែងអាចឈរឈ្មោះឱ្យគេជ្រើសរើសសាជាថ្មីបាន ។

**មាត្រា៣២.-**

**គ.ឱ.ជ.**មានឱសថការីចំនួន២(ពីរ)រូប តំណាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល១(មួយ)រូប និងតំណាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ១(មួយ)រូប ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ ។

**មាត្រា៣៣.-**

**គ.ឱ.ជ.**មានផ្នែកវិន័យមួយដែលមានសមាជិក៥(ប្រាំ)រូប ដឹកនាំដោយប្រធាន១(មួយ)រូប ជ្រើសតាំងក្នុងចំណោមសមាជិក៥(ប្រាំ)រូបនេះ ។

**មាត្រា៣៤.-**

បន្ទាប់ពីបានធ្វើការផ្លាស់ប្តូរសមាជិកចំនួន១/៣(មួយភាគបី)របស់ខ្លួន **គ.ឱ.ជ.**ត្រូវធ្វើការបោះឆ្នោតជ្រើសរើសផ្នែកវិន័យសាជាថ្មី ។

**មាត្រា៣៥.-**

**គ.ឱ.ជ.**បំពេញតួនាទីថ្នាក់ជាតិរបស់ខ្លួនក្នុងពេលបំពេញបេសកកម្ម ដូចមានចែងក្នុងមាត្រា២នៃព្រះរាជក្រឹត្យនេះ ។

គ.ឱ.ថ.ឃ្លាំមើលជាអាទិ៍ ការគោរពអនុវត្តរបស់សមាជិកនៃគណៈឱសថការីកម្ពុជាទាំងអស់ ឆ្ពោះនូវគរណីយកិច្ចវិជ្ជាជីវៈ និងគោលការណ៍ទាំងឡាយដែលបានកំណត់ក្នុងក្រមសីលធម៌ឱសថការី ។

គ.ឱ.ថ.សហការជាមួយគ.ឱ.រ.ខ. ក្នុងការសិក្សាដោះស្រាយបញ្ហាស្មុគស្មាញទាំងឡាយដែលពាក់ព័ន្ធនឹងប្រព្រឹត្តកម្មវិជ្ជាជីវៈរបស់ឱសថការី ។

គ.ឱ.ថ.បំពេញការងារនេះតាមរយៈផ្នែកនិងគណៈកម្មការទាំងឡាយរបស់ខ្លួន និងពិនិត្យសិក្សាបណ្តាបញ្ហាឬគម្រោងការទាំងឡាយដែលបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ ។

**មាត្រា៣៦.-**

គ.ឱ.ថ.ត្រូវកំណត់អំពីចំនួនទឹកប្រាក់ភាគទានឯកភាពមួយដែលសមាជិកម្នាក់ៗត្រូវបង់ នៅពេលសុំចុះបញ្ជី និងត្រូវបង់ប្រចាំឆ្នាំ ។

គ.ឱ.ថ.ត្រូវកម្រិតផងដែរនូវចំនួនភាគទានដែលគ.ឱ.រ.ខ.ត្រូវបង់ជូនទៅគ.ឱ.ថ. ទៅគ.ឱ.ភ. និងត្រូវរក្សាទុកនៅក្នុងគ.ឱ.រ.ខ. ដើម្បីធានាចំណាយក្នុងការបំពេញការងារទូទៅ ។ ការបង់ភាគទានគឺជាកាតព្វកិច្ចរបស់សមាជិកម្នាក់ៗ ។

គ.ឱ.ថ.គ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់គណៈឱសថការីកម្ពុជា និងអាចបង្កើតឬឧបត្ថម្ភដល់វណ្ណកម្មទាំងឡាយដែលជាផលប្រយោជន៍នៃវិជ្ជាជីវៈឱសថសាស្ត្រ ព្រមទាំងការងារសង្គ្រោះផ្សេងៗ ។

គ.ឱ.ថ.ត្រួតពិនិត្យការគ្រប់គ្រងរបស់គ.ឱ.រ.ខ. និង គ.ឱ.ភ. ។ គ.ឱ.រ.ខ.ត្រូវរាយការណ៍ជូនគ.ឱ.ថ. ជាមុនទើបចម្លងជូនទៅគ.ឱ.ភ. អំពីការបង្កើតអង្គការទាំងឡាយរបស់ខ្លួន ព្រមទាំងការចាត់ចែងរបស់អង្គការទាំងនោះ ។

**មាត្រា៣៧.-**

គ.ឱ.ថ.ត្រូវបង្កើតគណៈកម្មការសម្រាប់ចាត់ចែងហិរញ្ញវត្ថុ និងធ្វើសវនកម្មផ្ទៃក្នុង ។ សមាជិកនៃគណៈកម្មការនេះត្រូវជ្រើសរើសដោយគ.ឱ.ថ. ក្នុងចំណោមសមាជិកដែលមិនស្ថិតនៅក្នុងការិយាល័យរបស់គ.ឱ.ថ. ។

នៅដំណាច់ឆ្នាំនីមួយៗគណៈកម្មការនេះត្រូវធ្វើរបាយការណ៍អំពីការត្រួតពិនិត្យរបស់ខ្លួនជូនគ.ឱ.ថ. ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា៣៨.-**

ក្នុងអាណត្តិទី១នេះ សមាសភាព គ.ឱ.ថ.ត្រូវបានជ្រើសតាំងនិងឯកភាពដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដើម្បីដំណើរការឱ្យមានប្រសិទ្ធភាព ។

ក្នុងអំឡុងពេល៦(ប្រាំមួយ)ឆ្នាំដំបូងនៃអាណត្តិទីមួយ សមាសភាពការិយាល័យរបស់ គ.ឱ.រ.ខ. គ.ឱ.ភ.ត្រូវបានជ្រើសតាំងដោយសមាជិកភាពរបស់ខ្លួន និងទទួលស្គាល់ដោយគ.ឱ.ថ. ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៣៩.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវតែងតាំងក្រុមការងារមួយជាបណ្តោះអាសន្ន ដើម្បីរៀបចំដំណើរការបង្កើតគណៈឱសថការីកម្ពុជា ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤១.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា ៣៧៧. ១០០២. ១៦៤

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខ: ១៥៤ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**យុន មីនភេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦៣

## ស្តីពី

## ប្រព័ន្ធមតិកមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី កិច្ចការពារបេតិកភណ្ឌវប្បធម៌

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើ

ROYAUME DU CAMBODGE * LE ROYAL

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៦/00៣ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌវប្បធម៌អរូបី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៩ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០១០

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ព្រះរាជក្រឹត្យនេះមានគោលដៅកំណត់អំពីប្រព័ន្ធមតិកមនុស្សរស់ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

ព្រះរាជក្រឹត្យនេះមានគោលបំណងដូចតទៅ៖

-ធានាបាននូវការថែរក្សា និងការពារបេតិកភណ្ឌវប្បធម៌ជាតិឱ្យបានគង់វង្សទៅអនាគត

-គាំពារ និងលើកកម្ពស់ធនធានមតិកមនុស្សរស់នៅទូទាំងប្រទេស ដោយបង្កើតយន្តការសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ជាតិ និងការអភិវឌ្ឍចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេស ឱ្យមាននិរន្តរភាព

-បង្កើតប្រព័ន្ធសម្រាប់បន្តវេន និងផ្ទេរចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេស ផ្នែកបេតិកភណ្ឌវប្បធម៌ជាតិទៅជំនាន់ក្រោយ

-បង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសាធារណជន អង្គការជាតិ អន្តរជាតិ ដើម្បីធានាការអភិរក្ស និងការអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិ ជាពិសេសបេតិកភណ្ឌវប្បធម៌អរូបី ។

**មាត្រា៣.-**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តលើប្រជាពលរដ្ឋខ្មែរទាំងអស់ ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងព្រះរាជក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម៖

**-មត៌កមនុស្សរស់** សំដៅដល់បុគ្គល ឬក្រុមមនុស្សមានចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេស កម្រិតខ្ពស់បំផុត ដែលចាំបាច់ដល់ការបង្កើតភាពសម្រិតសម្រាំងនៃទិដ្ឋភាពជីវិតវប្បធម៌របស់ប្រជាជន និងអត្តិភាពបន្តនូវបេតិកភណ្ឌវប្បធម៌អរូបីរបស់ជាតិ ។

**-ប្រព័ន្ធមត៌កមនុស្សរស់** សំដៅដល់កន្សោមយន្តការគ្រប់គ្រងមត៌កមនុស្សរស់ តាមបទប្បញ្ញត្តិច្បាប់ ។

## ជំពូកទី២

## ការជ្រើសរើស និងការទទួលស្គាល់មត៌កមនុស្សរស់

**មាត្រា៥.-**

មត៌កមនុស្សរស់ត្រូវជ្រើសរើស និងទទួលស្គាល់ចេញពីទម្រង់ផ្សេងៗ នៃបេតិកភណ្ឌវប្បធម៌អរូបីដែលមានលក្ខខណ្ឌដូចខាងក្រោម៖

-មានតម្លៃលេចធ្លោ និងជាសក្ខីភាពនៃទេពកោសល្យដ៏ប៉ិនប្រសប់ក្នុងការបង្កើត និងការច្នៃប្រឌិតតាមឯកទេស នីមួយៗដែលជាឫសគល់នៃប្រពៃណីនិងវប្បធម៌របស់សង្គម

-មានចរិតលក្ខណៈបង្ហាញតម្លៃឯកនៃបេតិកភណ្ឌវប្បធម៌អរូបីក្នុងតំបន់ និងសហគមន៍

-មានសារៈសំខាន់ដែលអាចបញ្ជាក់ពីអត្តសញ្ញាណនៃតំបន់ សម្រាប់ប្រជាពលរដ្ឋ និងសង្គមជាតិ ។

លក្ខខណ្ឌទាំងបីខាងលើ ត្រូវយកមកពិចារណាដោយផ្តល់អាទិភាព នូវបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

-ប្រឈមនឹងការថយចុះនៃអ្នកមានចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេស ដែលកំពុងទទួលរងឥទ្ធិពលអវិជ្ជមាននៃសកលភាវូបនីយកម្ម

-ប្រឈមនឹងការបាត់បង់នូវសារៈសំខាន់នៃលក្ខណៈដើម

-ប្រឈមនឹងការបាត់បង់នូវកិត្យានុភាពវប្បធម៌ ។

**មាត្រា៦.-**

បុគ្គល ឬក្រុមមនុស្សណាមួយដែលត្រូវបានជ្រើសរើសជាមត៌កមនុស្សរស់ត្រូវមានគ្រប់លក្ខណសម្បត្តិដូចខាងក្រោម៖

-មានចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេស ស្ទាត់ជំនាញ ផ្នែកបេតិកភណ្ឌវប្បធម៌អរូបី

-មានមនសិការខ្ពស់ក្នុងការចូលរួមអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី

-មានសមត្ថភាពខ្ពស់ក្នុងការផ្ទេរចំណេះដឹងដោយមិនលាក់លៀម វិជ្ជាជីវៈ ជំនាញ ទេពកោសល្យ និងបច្ចេកទេស ទៅអ្នកជំនាន់ក្រោយ ដោយភាពស្មោះត្រង់ និងហ៊ានលះបង់ដើម្បីជំនាញ

-មានសីលធម៌រស់នៅថ្លៃថ្នូរ។

មតិកមនុស្សរស់មានក្រមសីលធម៌របស់ខ្លួនដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**មាត្រា៧.-**

មតិកមនុស្សរស់មានគោរមងារថ្នាក់ជាតិដែលទទួលស្គាល់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។

មតិកមនុស្សរស់មានគ្រឿងសម្គាល់របស់ខ្លួន។

## ជំពូកទី៣

## គណៈកម្មាធិការមតិកមនុស្សរស់

**មាត្រា៨.-**

គណៈកម្មាធិការមតិកមនុស្សរស់ មានសមាសភាពដូចតទៅ៖

| | |
|---|---|
| -រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| -តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| -តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| -តំណាង ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| -តំណាង ក្រសួងព័ត៌មាន | សមាជិក |
| -តំណាង ក្រសួងធម្មការ និងសាសនា | សមាជិក |
| -តំណាង ក្រសួងសុខាភិបាល | សមាជិក |
| -តំណាង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| -តំណាង រាជបណ្ឌិតសភាកម្ពុជា | សមាជិក |
| -សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | សមាជិក |
| -តំណាង គណៈកម្មការជាតិយូណេស្កូកម្ពុជា | សមាជិក |
| -តំណាង គណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក | សមាជិក |
| -តំណាង គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា | សមាជិក |
| -អគ្គនាយកបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | លេខាធិការអចិន្ត្រៃយ៍ |
| -មន្ត្រីជំនាញជាន់ខ្ពស់មួយចំនួននៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការមតិកមនុស្សរស់ ។

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការមតិកមនុស្សរស់ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា៩.-**

គណៈកម្មាធិការមតិកមនុស្សរស់មានភារកិច្ច ដូចតទៅ៖

-ពិនិត្យ និងសម្រេចទម្រង់សិល្បៈវប្បធម៌អរូបីណាមួយដែលកំពុងរងគ្រោះឈានទៅរកការបាត់បង់

-ស្រាវជ្រាវ ពិនិត្យ ជ្រើសរើស និងវាយតម្លៃលើបេក្ខភាពមតិកមនុស្សរស់ ដែលមានលក្ខណសម្បត្តិស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ នៃព្រះរាជក្រឹត្យនេះ

-ស្រាវជ្រាវរកមតិកមនុស្សរស់តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងតាមរយៈមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានី ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា

-រៀបចំយន្តការផ្ទេរចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសដល់អ្នកជំនាន់ក្រោយ

-ចាត់ចែង ប្រើប្រាស់មធ្យោបាយសម្ភារៈ ថវិកា និងគ្រឿងសម្គាល់ផ្សេងៗសម្រាប់មតិកមនុស្សរស់

-ធានាតម្កល់ទុករាល់ឯកសារអប់រំ និងផ្សព្វផ្សាយ ស្នាដៃរបស់មតិកមនុស្សរស់ ដើម្បីជាគុណប្រយោជន៍ចំពោះសង្គមជាតិ

-លើកទឹកចិត្តឱ្យមានការដាក់ពាក្យស្នើសុំជាបេក្ខជនមតិកមនុស្សរស់ ពីបុគ្គល ឬក្រុមមនុស្សទាំងឡាយដែលយល់ថាខ្លួនមានចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសវប្បធម៌ខ្ពស់

-ស្រាវជ្រាវ ពិនិត្យ និងវាយតម្លៃលើការស្នើសុំលាលែង និងការដកហូតតំណែងមតិកមនុស្សរស់ពីបុគ្គល ឬក្រុមមនុស្សដែលបានទទួលការតែងតាំងហើយ ។

## ជំពូកទី៤

## ភារកិច្ចមតិកមនុស្សរស់

**មាត្រា១០.-**

មតិកមនុស្សរស់មានភារកិច្ចសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដូចខាងក្រោម៖

-រៀបចំចងក្រងឯកសារសម្រាប់បង្ហាត់បង្រៀន ផ្សព្វផ្សាយ ដែលបម្រើប្រយោជន៍សង្គមជាតិ

-ផ្ទេរចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសរបស់ខ្លួនដោយគ្មានលាក់លៀមដល់អ្នកជំនាន់ក្រោយ តាមរយៈការបណ្តុះបណ្តាល

-ផ្សព្វផ្សាយចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសដែលខ្លួនមាន ឱ្យបានទូលំទូលាយដល់សាធារណជន ទូទៅតាមគ្រប់មធ្យោបាយ

-បន្តថែរក្សាឱ្យគង់វង្ស និងអភិវឌ្ឍចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសដែលសាមីខ្លួនបាន ទទួលកិត្តិយស

-ទទួលភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការមតិកមនុស្សរស់ និងរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា១១.-**

បុគ្គល ឬក្រុមមនុស្សដែលត្រូវបានទទួលស្គាល់ជាមតិកមនុស្សរស់ អាចរងការបដិសេធចោលនូវគោរមងារ និងផលប្រយោជន៍ទាំងអស់នេះវិញ ដោយមូលហេតុ៖

-អនុវត្តពុំបានទៅតាមកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា១០ នៃព្រះរាជក្រឹត្យនេះ

-ប្រព្រឹត្តផ្ទុយពីសីលធម៌វិជ្ជាជីវៈ ឬត្រូវបានតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ។

ប្រសិនបើមតិកមនុស្សរស់ទទួលមរណភាពក្នុងកេរ្តិ៍ឈ្មោះល្អ គោរមងារត្រូវបានរក្សា តែប្រាក់ឧបត្ថម្ភជីវភាពប្រចាំខែពីថវិកាជាតិត្រូវបញ្ចប់។

**មាត្រា១២.-**

ស្នាដៃបេតិកភណ្ឌវប្បធម៌អរូបីរបស់មតិកមនុស្សរស់ គឺជាកម្មសិទ្ធិរបស់មតិកមនុស្សរស់ ដែលត្រូវបានការពារ ដោយច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។

## ជំពូកទី៥
## ប្រភពធនធាននិងលាភការ

**មាត្រា១៣.-**

ប្រភពធនធានផ្គត់ផ្គង់ដល់មតិកមនុស្សរស់ និងគណៈកម្មាធិការមតិកមនុស្សរស់ បានមកពីថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក ក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

គណៈកម្មាធិការមតិកមនុស្សរស់ មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទាន សហប្រតិបត្តិការបរទេស និងពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

**មាត្រា១៤.-**

មតិកមនុស្សរស់ត្រូវទទួលបានផលប្រយោជន៍ និងលាភការដូចខាងក្រោម៖

-ប្រាក់ឧបត្ថម្ភជីវភាពប្រចាំខែពីថវិកាជាតិ។ បើមន្ត្រីរាជការទទួលការតែងតាំងជាមតិកមនុស្សរស់ ត្រូវទទួល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

បានប្រាក់បំណាច់ណាមួយដែលមានចំនួនច្រើនជាង ។

-ការឧបត្ថម្ភសម្ភារៈថវិកា និងមធ្យោបាយសម្រាប់បម្រើការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ។

ផលប្រយោជន៍ និងលាភការរបស់មតិកមនុស្សរស់ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៦.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០២១០.១៦៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ១៥៣ ច.ល

**ដើម្បីចម្លងចែក**

ភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**

**ស៊ុន ចិនគេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូន ឯកឧត្តម **ហាប់ ទូច** ឱ្យបំពេញមុខងារជា អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជំនួសឯកឧត្តម **ខាស សារុន** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.១០០២.១៦៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០*

លេខ:១៣៨ ច.ល

**[illegible] ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោកឧកញ៉ា **ជឹម សុផល**

នូវ

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

៣រ.ល.១០០៤.១៦៧

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០

លេខៈ ១៥៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ដល់

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ ៖

១. លោកជំទាវ ជា ខេង
២. ឯកឧត្តម ឆាយ សារ៉េត
៣. ឯកឧត្តម ខូយ សុខា
៤. ឯកឧត្តម ឧកញ៉ា ឌុយ គី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ពរល.១០០៧.១៦៩

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០

លេខ: ១៥៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- លោកជំទាវ មិន មាណវី

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១- លោក នូ វឌ្ឍនៈ
២- លោក ណៃ ចំណេចំ
៣- លោក រស់ បរម
៤- លោក ឃួយ ហាក់សុទ្ធិវុណ
៥- លោកឧកញ៉ា សុខ សុខា
៦- លោក ហ៊ីង បញ្ញាសិទ្ធិ

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- លោក គឹម ប៊ុណ្ណា
២- លោក ប៉ែន បូរាណ
៣- លោក អ៊ូ សារ៉េត
៤- លោក គួច ច័ន្ទត្រីស្នា
៥- លោក ឈួន ឃឿន
៦- លោក អ៊ូ សុខន
៧- លោក អ៊ុង ចង់ឿន

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១-លោក ជា ស៊ុនហៀង

ង- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ សេនា ចំពោះ :

១-លោក ជា សារុន

ច- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ សេនា ចំពោះ :

១-លោក គឹម សារ៉េត
២- លោក សុខ សុន្ទរ
៣- លោក ប៉ែន បុល្លីណា
៤- លោក ហួង សុជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣/៧.១០០៧.១៦៩

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០

លេខៈ ១៤៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនគេត

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ដូច**

**ក. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ៖**

១. ឯកឧត្តម **សួន រិនឌី**
២. លោកជំទាវ **កង ឧត្តរា**
៣. លោកជំទាវ **អៀង រ៉ុម**
៤. លោក **កែវ រិទ្ធី**
៥. ឯកឧត្តម **ឡុង សុវណ្ណា**
៦. លោកស្រី **ថោង ហុកគៀន**
៧. លោកជំទាវ **ចឹក ហេង**
៨. លោកស្រី **ខូយ ម៉ិនថាន**
៩. លោក **ទែន សារ៉ុម**
១០. លោក **ផាន់ សំអាន**
១១. លោកស្រី **ស្វាយ ច័ន្ទស៊ីសុផា**

**ខ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ៖**

១. លោក **ខាន់ ហ៊ាង**
២. លោក **ហាន នន**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១០០២.១៧០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០*

**លេខ: ១៥៤ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១០
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជ័នកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | ឃុន | វណ្ណា | ០០៩៨៩៦ |
| ២ | វរសេនីយ៍ឯក | ទ៉ាន់ | ជារ៉ាសិទ្ធិ | ០០៥២២៣ |
| ៣ | វរសេនីយ៍ឯក | ពៅ | សំអាត | ០០៤៩៥៧ |

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :-

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | សំ | យាន | ០០២៦៩២ |
| ២ | វរសេនីយ៍ឯក | អ៊ុន | សារុន | ០០២៧០៥ |
| ៣ | អនុសេនីយ៍ឯក | ស្រី | សាម៉ុន | ០៥៦២៣០ |

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :-

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | កើត | សុវណ្ណារិទ្ធ | ០០៤០៨៣ |
| ២ | វរសេនីយ៍ទោ | ឯម | វណ្ណារិទ្ធ | ០១៦៤៧៤ |
| ៣ | វរសេនីយ៍ទោ | កែប | ម៉ារ៉ាឌី | ០២៩៦០៧ |
| ៤ | វរសេនីយ៍ទោ | ប៊ុច | ឈាង | ០០៩៥៨០ |
| ៥ | វរសេនីយ៍ទោ | ចាន់ | ធុន្នី | ០១៧៨៤៧ |
| ៦ | វរសេនីយ៍ត្រី | ប៉ែន | សុខុម | ២២៩៥១៥ |
| ៧ | អនុសេនីយ៍ទោ | ផាន់ | វិសាល | ០៥៧៨៤៧ |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល. ១០០៤. ១៧៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១០

លេខ: ១៦០ ច.ល

ដើម្បីចម្លងចែក

ភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១០

[illegible]ការគណៈរដ្ឋាភិបាល

[illegible] ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៧៥

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

លោកជំទាវ Zhang Jinfeng

នូវ

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ចរល.១០០៥.១៧៤

**នរោត្តម សីហមុនី**

**លេខៈ១៥៦ ច.ល**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១០*

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៧. អនក្រ.បក

## អនុក្រឹត្យ

### ស្ដីពី

### ការធ្វើអនុបយោគ

### ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្ដីពីបែបបទនៃឯកជនភាវូបនីយកម្ម

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ រួមមាន:

-ទីតាំងការិយាល័យគ្រឿងយន្តកសិកម្ម ស្ថិតនៅភូមិកសិកម្ម ឃុំស្រងែ ខេត្តសៀមរាប ដែលមានទំហំដី ១៥.៤០០ ម៉ែត្រក្រឡា។

-ទីតាំងអគារចាស់ៗ ចំនួន០៤កន្លែង របស់មន្ទីរពត៌មាន ខេត្តក្រចេះ រួមមាន:

.អគារទំហំ ១៤០ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវសុរាម្រិត ភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ។

.អគារទំហំ ៣៩ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវសុរាម្រិត ភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ។

.អគារទំហំ ៣៣ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវលេខ៨ ភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ។

.អគារទំហំ ៦៦ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវលេខ៨ ភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ។

-ទីតាំងសាលាឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មានទំហំដី ៣.០០៩ ម៉ែត្រក្រឡា។

-ប៉ុស្តិ៍នគរបាល រដ្ឋបាល សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមានទំហំអគារ ៤៨ ម៉ែត្រក្រឡា។

-ទីតាំងការិយាល័យរដ្ឋបាលព្រៃឈើ និងការិយាល័យជលផល រាជធានីភ្នំពេញ ស្ថិតនៅកែងផ្លូវលេខ៦៣ និងផ្លូវលេខ ១០២ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានទំហំដី ៥៩០ម៉ែត្រក្រឡា។

-ទីតាំងអតីតរោងពុម្ពនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តបាត់ដំបង ស្ថិតនៅផ្លូវលេខ១ ភូមិ២០ ឧសភា សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដែលមានទំហំដី ២១៤ ម៉ែត្រក្រឡា។

-ទីតាំងការិយាល័យចំណុះ និងទីតាំងមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ រួមមានៈ

.ដីការិយាល័យគ្រឿងយន្តកសិកម្ម ស្ថិតនៅភូមិគោកស្វាយ ឃុំឬស្សីក្រោក ស្រុកមង្គលបុរី ដែលមានទំហំ ១.៤៥៤ ម៉ែត្រក្រឡា។

.ដីការិយាល័យរុក្ខាប្រមាញ់ ការិយាល័យជលផល និងដីទំនេររបស់មន្ទីរកសិកម្ម ស្ថិតនៅផ្លូវលេខ ៦៩ ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ដែលមានទំហំ ៧.៨៧២ ម៉ែត្រក្រឡា។

.ដីស្ថានីយ៍កសិកម្មស្ពានក្រឡ ស្ថិតនៅភូមិបន្ទាយនាង ឃុំបន្ទាយនាង ស្រុកមង្គលបូរី ដែលមានទំហំ ២៣៧.៣០៦ ម៉ែត្រក្រឡា។

.មន្ទីរកសិកម្ម ស្ថិតនៅក្នុងប្លុកអគារអក្សរអ៊ុយ ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ដែលមានទំហំដីសរុប ៦៤០ម៉ែត្រក្រឡា។

-ទីតាំងអគ្គនាយកដ្ឋានពត៌មាន និងសោតទស្សន៍ នៃក្រសួងពត៌មាន ស្ថិតនៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានទំហំដី ១.៦២០ ម៉ែត្រក្រឡា។

**មាត្រា ២.-**

ការលប់និងការកត់ត្រាផ្ទេរនៃការដោះដូរទៅក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សាលារាជធានីភ្នំពេញ សាលាខេត្តសៀមរាប សាលាខេត្តព្រៃវែង សាលាខេត្តក្រចេះ សាលាខេត្តបន្ទាយមានជ័យ និង សាលាខេត្តបាត់ដំបង។

**មាត្រា ៣.-**

ការបំពេញបែបបទផ្ទេរកម្មសិទ្ធិរបស់ភាគីឯកជនលើទីតាំងរបស់រដ្ឋត្រូវប្រព្រឹត្តទៅតាមច្បាប់ និងគោលការណ៍កំណត់ជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប អភិបាលខេត្តបាត់ដំបង អភិបាលខេត្តបន្ទាយមានជ័យ អភិបាលខេត្តក្រចេះ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ នៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
